វិទ្យាស្ថានបើកទូលាយ Open Institute

CCIM cambodian center for independent media

People Health Development

KYSD DYNAMISM FOR BETTERMENT OF SOCIETY

# លទ្ធផលសង្ខេបវេទិកាពិភាក្សាលើកទី២

# ស្តីពី

## "តួនាទីយុវជនក្នុងការពង្រឹងការអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន"

ឧបត្ថម្ភថវិកាដោយ ៖ SPIDER



# "តួនាទីយុវជនក្នុងការពង្រឹងការអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន"

រៀបចំដោយ ៖ សម្ព័ន្ធភាពជាតិ ឃុំ សង្កាត់ និង អង្គការវិទ្យាស្ថានបើកទូលាយ

កាលបរិច្ឆេទ ៖ ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៣

សមាជិកចូលរួមក្នុងវេទិកា៖ ៤០នាក់(ស្ត្រី២០នាក់ បុរស២០នាក់)

- តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ (៨រូប)
- តំណាងស្ថាប័នរាជរដ្ឋាភិបាល (២រូប)
- តំណាងម្ចាស់ជំនួយ (១រូប)
- តំណាងអង្គការមិនមែនរដ្ឋាភិបាល (២៥រូប)
- តំណាងអ្នកសារព័ត៌មាន (៣រូប)
- តំណាងក្រុមហ៊ុនឯកជន (១រូប)

# គោលបំណងនៃវេទិកាពិភាក្សា





•ផ្តល់ចំណេះដឹងដល់យុវជនស្តីពីតួនាទី ភារកិច្ច និង ការទទួលខុសត្រូវរបស់ឃុំ សង្កាត់ យោងតាមច្បាប់ស្តីពី "ការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់" សម្រាប់ការចូលរួមដ៏មានប្រសិទ្ធភាពជាមួយក្រុមប្រឹក្សាឃុំ សង្កាត់។

•កំណត់យុទ្ធសាស្រ្តនៃការចូលរួមដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរនៃការធ្វើសេចក្តីសម្រេចចិត្តចាប់តាំងពីការកសាងផែនការ ការអនុវត្តន៍ផែនការ គោលនយោបាយ កម្មវិធី និង សេវាកម្មដែលផ្តល់ជូនជាមួយនឹងគុណភាពប្រសិទ្ធភាពនៅថ្នាក់ក្រោមជាតិជាពិសេសគឺថ្នាក់ឃុំ សង្កាត់។

បទបង្ហាញលើប្រធានបទចំនួន ៣៖

- កម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនិងផែនការអនុវត្ត៣ឆ្នាំរំកិល ដោយតំណាងអង្គភាពវិភាគ និងអភិវឌ្ឍគោលនយោបាយរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៃក្រសួងមហាផ្ទៃ
- ការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដំណើរការនៃកម្មវិធីវិនិយោគ (CIP) ផែនការអភិវឌ្ឍ(CDP) សកម្មភាពឃុំ/សង្កាត់ និង របៀបដែលយុវជនអាចចូលរួមក្នុងដំណើរការទាំងនោះបាន ដោយតំណាងក្រុមប្រឹក្សាពីខេត្តសៀមរាប
- បទពិសោធន៍នៃការធ្វើសមាហរណ៍ កម្មយុវជនក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាន ដោយតំណាងអង្គការកម្មវិធីអភិវឌ្ឍន៍យុវជន

# សំណួរពិភាក្សា

១ ហេតុអ្វីប្រជាពលរដ្ឋដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការអភិបាលកិច្ចល្អ?

២ តើយុវជនមានតួនាទីយ៉ាងដូចម្ដេចខ្លះដើម្បីរួមចំណែកក្នុងអភិបាលកិច្ចល្អក្នុងសហគមន៍របស់ពួកគេ?

៣ តើយុវជនអាចចូលរួមក្នុងសកម្មភាពនានារបស់ឃុំ សង្កាត់បានយ៉ាងដូចម្ដេច?

៤ តើយុវជនទទួលបានផលប្រយោជន៍អ្វីខ្លះពីការចូលរួមក្នុងការងារសហគមន៍ជាពិសេសការងារអភិបាលកិច្ចឃុំ សង្កាត់?

៥ តើមានយុទ្ធសាស្ត្រអ្វីខ្លះដែលអាចលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងពង្រឹងកិច្ចការមូលដ្ឋាននិងអភិបាលកិច្ចល្អ?

# លទ្ធផលនៃការពិភាក្សា

## ហេតុអ្វីប្រជាពលរដ្ឋដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការអភិបាលកិច្ចល្អ?

តួនាទីប្រជាពលរដ្ឋក្នុងអភិបាលកិច្ចល្អគួរតែមាន៨ចំណុចសំខាន់ៗមានដូចជា៖ ការចូលរួមពេញលេញ ការផ្សព្វផ្សាយទូទៅ តួនាទីច្បាប់ តម្លា ភាព សមភាព ប្រសិទ្ធផលនិងប្រសិទ្ធភាពគណនេយ្យភាព និងការទទួលខុសត្រូវ។ ប្រជាពលរដ្ឋគួរតែមានតួនាទីសកម្ម និងយល់អំពីតួនាទីរបស់ពួកគេដើម្បីធានាបានថាការងារនេះនឹងប្រព្រឹត្តទៅមុខដោយរលូន។

# លទ្ធផលនៃការពិភាក្សា

## តើយុវជនមានតួនាទីយ៉ាងដូចម្តេចខ្លះដើម្បីរួមចំណែកក្នុងអភិបាលកិច្ចល្អក្នុងសហគមន៍របស់ពួកគេ?

យុវជនគួរតែស្គាល់ពីតម្លៃរបស់ខ្លួនឯង និងកម្រិតនៃការចូលរួមរបស់យុវជននៅក្នុងសង្គមសម្រាប់ជាតិ។ យុវជនមានតួនាទីសំខាន់ផ្សេងៗ ដូចជាចែករំលែកព័ត៌មាន អភិវឌ្ឍសមត្ថភាពខ្លួនឯង ស្វះស្វែងទទួលយកព័ត៌មាន និងធ្វើជាគំរូល្អមួយដល់សង្គម។ ជាពិសេស ត្រូវចេះសហការជាមួយអាជ្ញាធរក្នុងតំបន់ដើម្បីធានាសុវត្ថិភាពសន្តិសុខរបស់សហគមន៍។ ក្នុងកិច្ចពិភាក្សាក៏បានសម្តែងនៅការព្រួយបារម្ភផងដែរថាយុវជនមួយចំនួនតូចមានការពាក់ព័ន្ធជាមួយគ្រឿងញៀន និងគ្រឿងស្រវឹង និងមួយចំនួនចំណាយពេលវេលាជាច្រើនជាមួយវីដេអូហ្គេម។

# លទ្ធផលនៃការពិភាក្សា

## តើយុវជនមានតួនាទីយ៉ាងដូចម្ដេចខ្លះដើម្បីរួមចំណែកក្នុងអភិបាលកិច្ចល្អក្នុងសហគមន៍របស់ពួកគេ?

យុវជនគួរតែចូលរួមអង្កេតនូវការលូតលាស់និងការរីកខ្សោយនៃការអភិវឌ្ឍថ្នាក់ក្រោម។ ពួកគេគួរតែមានតួនាទីសកម្មក្នុងថ្នាក់តំបន់ដើម្បីចូលរួមតាមដានការចាយវាយរបស់ផែនការហិរញ្ញវត្ថុរបស់គម្រោងអភិវឌ្ឍឃុំ/សង្កាត់។ មូលនិធិរបស់ការអភិវឌ្ឍគួរតែមានការចូលរួមរបស់យុវជន។

# លទ្ធផលនៃការពិភាក្សា

## តើយុវជនទទួលបានផលប្រយោជន៍អ្វីខ្លះពីការចូលរួមក្នុងការងារសហគមន៍ជាពិសេសការងារ អភិបាលកិច្ចឃុំ សង្កាត់?

យុវជន និងមនុស្សវ័យចំណាស់អាចផ្តល់ផលប្រយោជន៍អោយគ្នាទៅវិញទៅមក តាមរយៈចំណេះដឹងនិងសមត្ថភាព។ ការចូលរួមរបស់យុវជននឹងជំរុញលើកកម្ពស់អភិបាលកិច្ចល្អ។ ការជួយរបស់យុវជនមានអត្ថន័យយ៉ាងសំខាន់សម្រាប់ផ្តល់អោយការងារឃុំ សង្កាត់កាន់តែមានមុខងារងាយស្រួលនិងយ៉ាងមានប្រសិទ្ធភាព។ ជាពិសេសជាងនេះទៅទៀតការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍរបស់ឃុំ សង្កាត់ ដែលនឹងជួយកាត់បន្ថយនូវការចាត់ទុកយុវជនគឺជាបញ្ហារបស់សង្គម។ យុវជននឹងផ្តល់នូវគំនិតថ្មីៗនិងទស្សនៈល្អៗ។ យុវជននឹងធ្វើអោយមានការផ្លាស់ប្តូរនូវអនាគតយ៉ាងពិតប្រាកដនាពេលអនាគត។

# លទ្ធផលនៃការពិភាក្សា

## តើមានយុទ្ធសាស្រ្តអ្វីខ្លះដែលអាចលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងពង្រឹងកិច្ចការមូលដ្ឋាន និងអភិបាលកិច្ចល្អ?

ដើម្បីលើកកម្ពស់តួនាទីរបស់យុវជនក្នុងការអភិវឌ្ឍថ្នាក់ក្រោមនិងអភិបាលកិច្ចល្អ គួរតែ បង្កើតនូវវេទិកាសិក្ខាសាលានិងការពិភាក្សាតុមូលដែលជាឱកាសសម្រាប់ផ្លាស់ប្តូរយោបល់និងបទពិសោធន៍គ្នាទៅវិញទៅមក សម្រាប់ធ្វើការជាមួយយុវជន។ ជាពិសេសជាងនេះទៅទៀត លើកកម្ពស់ការផ្សព្វផ្សាយជាសាធារណៈ និងមិត្តអប់រំមិត្ត ដើម្បីទាក់ទាញយកចំណាប់អារម្មណ៍ និងជាពិសេសធ្វើការបង្ហាញនូវលទ្ធផលស្នាដៃរបស់យុវជនគំរូៗក្នុងការដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ ហើយវានឹងធ្វើអោយយុវជនដ៏ទៃទៀតកាន់តែមានចំណាប់អារម្មណ៍បន្ថែមទៀត។

សូមអរគុណ!